ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

## គឆ.ខប

## សម្រាប់

## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
## នីតិកាលទី៦ ឆ្នាំ២០១៨

(ថ្ងៃអាទិត្យ ទី២៩ ខែកក្កដា ឆ្នាំ២០១៨)

# មាតិកា


**គោលបំណង** ............................................................ ១

I. **សមាសភាព រចនាសម្ព័ន្ធ ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប** ............ ២

១. សមាសភាព និងរចនាសម្ព័ន្ធរបស់ គធ.ខប ............................................ ២

ក. លេខាធិការដ្ឋាននៃ គធ.ខប (លគធ.ខប) ............................................ ២

ខ. អនុគណៈកម្មការបច្ចេកទេស ............................................ ៣

គ. អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល ............................................ ៣

ឃ. ក្រុមត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅ គធ.ខប ............................................ ៣

ង. ក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គធ.ខប ............................................ ៤

ច. ក្រុមសម្របសម្រួលនៅ គធ.ខប ............................................ ៤

២. ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប ............................................ ៥

II. **ការប្រមូល និងការបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត មក គ.ជ.ប** .. ៦

III. **ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប** ............................................ ៧

១. ទីតាំងនៃមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ............ ៧

២. សន្តិសុខ និងសុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ............ ៨

៣. ការគ្រប់គ្រងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ............ ៨

ក. ការអនុញ្ញាត ............................................ ៨

ខ. បម្រាម ............................................ ៩

IV. **ការប្រគល់ និងការទទួលកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬ/និងស្បោង «គ មានបណ្តឹង» និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គធ.ខប** ............ ៩

១. ការប្រគល់ ............................................ ៩

២. ការទទួល ............................................ ៩

V. **ការដាក់ និងការទទួលពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គឃ.សប នៅ គធ.ខប** ............................................ ១១

១. អ្នកមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ ............................................ ១១

២. ការបំពេញពាក្យបណ្តឹង (ទ.១២០២) ............................................ ១១

៣. ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប ............................................ ១១

ក. ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ .......... ១២
ខ. ពាក្យបណ្ដឹងដែលបានទទួលនៅ គធ.ខប ក្រោយរយៈពេលកំណត់ .......... ១២
គ. ពាក្យបណ្ដឹងដែលបានទទួលនៅ គធ.ខប ក្នុងរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់គ្រប់គ្រាន់...... ១៣
VI. **ប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត**.១៣
១. ការណែនាំក្រុមត្រួតពិនិត្យលទ្ធផល .......... ១៣
២. ការកំណត់ និងការរៀបចំតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ .......... ១៤
៣. ការកំណត់ និងការរៀបចំបន្ទប់សម្រាប់ក្រុមត្រួតពិនិត្យលទ្ធផល .......... ១៥
VII. **ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់** .......... ១៥
១. ដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត .......... ១៦
២. ការពិនិត្យសម្រេចរបស់ គធ.ខប នៅលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងការប្រើប្រាស់ .......... ១៧
៣. ការរៀបចំសម្ភារ ឯកសារឡើងវិញ .......... ១៧
VIII. **ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ដាក់នៅ គឃ.សប និងនៅ គធ.ខប** .......... ១៨
១. ករណីគ្មានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬពុំមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត .......... ១៨
២. ករណីមានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោត .......... ១៨
ក. នីតិវិធីនៃការបើកកញ្ចប់សុវត្ថិភាព «ក» .......... ១៨
ខ. របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត .......... ២០
គ. ឯកសារដែលត្រូវដាក់ជូន គធ.ខប ដើម្បីសម្រេច .......... ២០
ឃ. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតឡើងវិញ .......... ២១
៣. ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ .......... ២១
ក. ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ .......... ២១

ខ. ប្រសិនបើ គធ.ឃប សម្រេចយល់ព្រមកែតម្រូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ក្នុងករណីរកឃើញកំហុសឆ្គងក្នុងការគណនាតួលេខ .២២
គ. ប្រសិនបើ គធ.ឃប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ .. ២៣
៤. ការបញ្ជូន និងការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតក្នុងឃុំ សង្កាត់ដែល គធ.ឃប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ..... ២៦
ក. ការបញ្ជូន ..... ២៦
ខ. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោត ..... ២៦
គ. លិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) ..... ២៧
IX. **ការបូកសរុប និងការបំពេញលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត** ..... ២៨
១. ការរៀបចំ និងការទុកដាក់កម្មវិធីបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ..... ២៨
២. ការផ្ទៀងផ្ទាត់ឡើងវិញ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ..... ២៩
៣. ការបំពេញ និងការប្រើប្រាស់ទម្រង់បែបបទនៅ គធ.ឃប ..... ២៩
ក. តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ..... ២៩
ខ. កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ..... ៣០
គ. ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ..... ៣០
X. **ការវេចខ្ចប់ និងការបញ្ជូនលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងរាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប** ..... ៣១
១. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ណាដែល គធ.ឃប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផល .. ៣២
២. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ណាដែល គធ.ឃប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ..... ៣២
ក. ការវេចខ្ចប់កញ្ចប់ «ឃ ពិសេស» ..... ៣២
ខ. ការវេចខ្ចប់ស្បោង «ឃ» នៃឃុំ សង្កាត់ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ..... ៣៣
គ. ការវេចខ្ចប់ស្បោង «ឃ មានបណ្ដឹង» ..... ៣៤
ឃ. ការបញ្ជូន និងការប្រគល់ ទទួល ..... ៣៥
ង. ការវេចខ្ចប់សម្ភារ ឯកសារនៅសល់បញ្ជូនទៅ គ.ជ.ប ..... ៣៥
**ទម្រង់បែបបទសម្រាប់ប្រើប្រាស់នៅ គធ.ឃប** ..... ៣៦

# អក្សរកាត់

| | | |
|---|---|---|
| ១. | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៣. | លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ៤. | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| ៥. | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| ៦. | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៧. | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ច.ប.ត.រ |
| ៨. | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ប.ន.ត.រ |
| ៩. | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១០. | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |
| ១១. | ទម្រង់បែបបទលេខ | ទ. |

# គោលបំណង

ដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ នាថ្ងៃអាទិត្យ ទី២៩ ខែកក្កដា ឆ្នាំ២០១៨ ប្រព្រឹត្តទៅបានដោយរលូន តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប បានរៀបចំចងក្រងសៀវភៅណែនាំ គធ.ខប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ នេះឡើង ដើម្បីជាជំនួយ និងលើកកម្ពស់ការយល់ដឹងដល់ គធ.ខប អំពីការទទួលខុសត្រូវលើភារកិច្ចដ៏ច្រើនដែលច្បាប់បោះឆ្នោតអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ឬដែល គ.ជ.ប បានកំណត់ក្នុង ប.ន.ត.រ ជាពិសេសអំពី៖

- ការទទួល និងការដោះស្រាយពាក្យបណ្តឹងក្រោមសមត្ថកិច្ចរបស់ខ្លួន។
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងនៅ គធ.ខប។
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលមានពាក្យបណ្តឹងនៅ គធ.ខប។
- ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតបញ្ជូនមក គ.ជ.ប ករណី គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់។
- ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតបញ្ជូនមក គ.ជ.ប ករណី គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យណាមួយ ឬច្រើនក្នុងឃុំ សង្កាត់។

គ.ជ.ប សង្ឃឹមថា គធ.ខប នឹងយកចិត្តទុកដាក់សិក្សាស្វែងយល់ និងអនុវត្តតាមការណែនាំក្នុងសៀវភៅនេះ ដើម្បីសម្រេចភារកិច្ចបានត្រឹមត្រូវ ទាន់ពេលវេលា និងមានតម្លាភាព។

# គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប)

## I. សមាសភាព រចនាសម្ព័ន្ធ ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប

### ១. សមាសភាព និងរចនាសម្ព័ន្ធរបស់ គធ.ខប

គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គឺជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលត្រូវតែងតាំងដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន។

គធ.ខប ត្រូវមានសមាសភាពចំនួន ៥ ឬ៧រូប ដែលរួមមាន៖

- ប្រធាន ១រូប
- អនុប្រធាន ១រូប
- សមាជិក ៣ ឬ៥រូប

ចំនួនជាក់ស្តែងនៃសមាជិក គធ.ខប ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

គធ.ខប មានលេខាធិការដ្ឋាន អនុគណៈកម្មការបច្ចេកទេស អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល និងអនុគណៈកម្មការផ្សេងៗទៀតតាមការចាំបាច់ ជាជំនួយការ។




#### ក. លេខាធិការដ្ឋាននៃ គធ.ខប (លគធ.ខប)

លេខាធិការដ្ឋាននៃ គធ.ខប មានសមាសភាពដូចខាងក្រោម៖

- ប្រធាន ១រូប
- អនុប្រធាន ១រូប
- សមាជិកយ៉ាងច្រើន ៥រូប

នៅក្នុងដំណាក់កាលបោះឆ្នោត លធ.ខប បំពេញភារកិច្ចជាជំនួយការឱ្យ គធ.ខប ហើយដែលត្រូវហៅថា លេខាធិការដ្ឋាននៃ គធ.ខប (លគធ.ខប)។

### ខ. អនុគណៈកម្មការបច្ចេកទេស

អនុគណៈកម្មការបច្ចេកទេសនៃ គជ.ខប មាន ៥ផ្នែក និងមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| -ប្រធាន លគជ.ខប | ជាប្រធាន |
| -អនុប្រធាន លគជ.ខប | ជាអនុប្រធាន |
| -សមាជិក គជ.ខប | ជាប្រធានផ្នែកនីមួយៗ |
| -សមាជិក លគជ.ខប | ជាអនុប្រធានផ្នែកនីមួយៗ។ |

ផ្នែកទាំង ៥ នៃអនុគណៈកម្មការបច្ចេកទេស គឺ៖

- ផ្នែករដ្ឋបាល
- ផ្នែកប្រតិបត្តិការ និងបញ្ជីបោះឆ្នោត
- ផ្នែកហិរញ្ញវត្ថុ
- ផ្នែកបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត ព័ត៌មាន និងទំនាក់ទំនងសាធារណៈ
- ផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត។

សមាជិក គជ.ខប នីមួយៗត្រូវបានចាត់តាំងជាប្រធានផ្នែកនៃអនុគណៈកម្មការបច្ចេកទេសនីមួយៗ។

### គ. អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល

អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| -ប្រធាន គជ.ខប | ជាប្រធាន |
| -អនុប្រធាន គជ.ខប | ជាអនុប្រធាន |
| -ប្រធាន និងអនុប្រធាន លគជ.ខប | ជាសមាជិក |

អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួលមានផ្នែកពាក់ព័ន្ធទាំងអស់ជាជំនួយការ។

### ឃ. ក្រុមត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅ គជ.ខប

គជ.ខប ត្រូវតែងតាំងក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប មួយក្រុម ឬច្រើនក្រុម ដោយយោងតាមចំនួនតិច ឬច្រើននៃឃុំ សង្កាត់ ក្នុងរាជធានី ខេត្តនីមួយៗ ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងតែងតាំងមួយក្រុមផ្សេងទៀតដើម្បីបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន។

ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗដែលត្រូវបានតែងតាំង អាចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ចំនួនតិចជាង ១០ ឬច្រើនជាង ១០ និងអាចបែងចែកឱ្យទទួលបន្ទុកឃុំ សង្កាត់ ក្នុងក្រុង ស្រុក ខណ្ឌមួយ ឬលើសពីមួយ។

សមាសភាពនៃក្រុមត្រួតពិនិត្យលទ្ធផល ត្រូវជ្រើសតាំងពីក្នុងចំណោមសមាសភាពអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប និងមន្ត្រីនៃ លគធ.ខប ក្នុងនោះត្រូវយកចិត្តទុកដាក់ចំពោះមន្ត្រីណាដែលពេលនោះ មិនសូវមានការងារមមាញឹក ដូចជាគ្រូបង្ហាត់ជាដើម។ គធ.ខប អាចលើកសំណើសុំតែងតាំងសមាជិកនៃ គឃ.សប ដែលស្ថិតនៅជិត លគធ.ខប បញ្ចូលក្នុងក្រុមត្រួតពិនិត្យលទ្ធផល ក្នុងករណីពុំមានមន្ត្រីបុគ្គលិកគ្រប់គ្រាន់។

ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ មានសមាសភាពចំនួន ៤រូប ដូចខាងក្រោមៈ

- ប្រធាន ១រូប

(ដែលជាសមាជិកអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប ឬមន្ត្រីនៃ លគធ.ខប)

- អនុប្រធាន ១រូប
- លេខាធិការ ១រូប
- ជំនួយការ ១រូប។

ក្រុមត្រួតពិនិត្យលទ្ធផល មានភារកិច្ចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ តាមចំនួនឃុំ សង្កាត់ ដែលក្រុមទទួលបន្ទុកប៉ុណ្ណោះ។

**ង. ក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គធ.ខប**

ប្រធាន លគធ.ខប ត្រូវទទួលបន្ទុកដឹកនាំក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តដោយផ្ទាល់។ ក្រុមបូកសរុបលទ្ធផល មានសមាសភាព ដូចខាងក្រោមៈ

- ប្រធានផ្នែករដ្ឋបាល ១រូប
- ប្រធានផ្នែកប្រតិបត្តិការ ១រូប
- មន្ត្រីចេះប្រើប្រាស់កុំព្យូទ័រ មួយចំនួនតាមការចាំបាច់
- ការីកុំព្យូទ័រ ឬមន្ត្រីដែលមានចំណេះដឹងខាងការប្រើប្រាស់អ៊ីមែល ១រូប។

**ច. ក្រុមសម្របសម្រួលនៅ គធ.ខប**

ក្រុមសម្របសម្រួលនៅ គធ.ខប មានសមាសភាព ដូចខាងក្រោមៈ

- ប្រធាន លគធ.ខប ប្រធាន
- សមាជិក គធ.ខប ទទួលបន្ទុកផ្នែកប្រតិបត្តិការ និងបញ្ជីបោះឆ្នោត អនុប្រធាន
- សមាជិក គធ.ខប ទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត សមាជិក
- ជំនួយការបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត ព័ត៌មាន និងទំនាក់ទំនងសាធារណៈ (គ្រូបង្ហាត់) សមាជិក

- មន្ត្រីប្រតិបត្តិការ និងភស្តុភារ សមាជិក
- លេខាធិការ សមាជិក

សមាសភាពជាក់ស្តែងត្រូវចាត់តាំងតាមរយៈលិខិតបង្គាប់ការរបស់ គធ.ខប។

## ២. តួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប

គធ.ខប ត្រូវទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅឃុំ សង្កាត់ ក្នុងរាជធានី ខេត្តរបស់ខ្លួនតាមការប្រគល់សិទ្ធិអំណាច និងត្រួតពិនិត្យនីត្យានុកូលភាព ដោយ គ.ជ.ប។ គធ.ខប ត្រូវ៖

- ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមរយៈការបោះឆ្នោតជាសម្ងាត់។
- អនុវត្តផែនការមេ គ្រប់គ្រងថវិការបស់ខ្លួន ចុះបញ្ជី និងថែរក្សាបញ្ជីសារពើភ័ណ្ឌនៃសម្ភារ បរិក្ខារសម្រាប់ការបោះឆ្នោត និងគោរពប្រតិទិននៃការបោះឆ្នោត។
- គោរព និងអនុវត្តច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងគោលការណ៍ណែនាំរបស់ គ.ជ.ប និងក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត។
- ចាត់វិធានការពាក់ព័ន្ធទៅនឹងកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងដំណើរការបោះឆ្នោត។
- តាមដាន ត្រួតពិនិត្យការងារគ្រប់គ្រង និងប្រតិបត្តិការរបស់ គឃ.សប។
- បែងចែកសម្ភារ បរិក្ខារបោះឆ្នោតជូន គឃ.សប។
- ចែកចាយរាល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត។
- លើកគម្រោង និងអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីការបោះឆ្នោតក្នុងក្របខ័ណ្ឌរាជធានី ខេត្ត ដោយយោងតាមការណែនាំរបស់ គ.ជ.ប។
- លើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីដំណើរការបោះឆ្នោតដោយធ្វើការសម្របសម្រួលការងារអប់រំអ្នកបោះឆ្នោតនៅក្នុងក្របខ័ណ្ឌរាជធានី ខេត្ត ដោយសហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាលនានា។
- សម្របសម្រួល និងត្រួតពិនិត្យការឃោសនាបោះឆ្នោតនៅក្នុងរាជធានី ខេត្ត។
- ចាត់គ្រប់វិធានការ ដើម្បីធានាឱ្យមានភាពស្មើគ្នាក្នុងការប្រើប្រាស់អគារ ឬទីសាធារណៈដល់គណបក្សនយោបាយឈរឈ្មោះ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។
- ដំណើរការកម្មវិធីផ្សព្វផ្សាយព័ត៌មាន។
- លើកសំណើសុំ គ.ជ.ប តែងតាំងសមាសភាព គឃ.សប និង គ.ក.ប ក្នុងរាជធានី ខេត្ត និងធ្វើតារាងប្រាក់កម្រៃសម្រាប់សមាជិក និងមន្ត្រីនៃ គធ.ខប គឃ.សប និង គ.ក.ប តាមការណែនាំរបស់ គ.ជ.ប។
- ចាត់ចែង និងសម្របសម្រួលការអនុវត្តសេចក្តីសម្រេចរបស់ គ.ជ.ប ស្តីពីនីតិវិធី

បញ្ជូល បញ្ជូន ត្រួតពិនិត្យ និងផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋមនៅតាមរាជធានី ខេត្តរៀងៗខ្លួន ដោយសហការជាមួយអនុគណៈកម្មការសម្របសម្រួលរបស់ គ.ជ.ប និង គឃ.សប។

- តាមដានការងារគ្រប់គ្រង និងចាត់ចែងរបស់ គឃ.សប ក្នុងការបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន។
- រៀបចំចាត់ចែងប្រមូល និងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន។
- រៀបចំវេចខ្ចប់ និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ឬរាជធានី ខេត្តរបស់ខ្លួន ព្រមទាំងសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោតពាក់ព័ន្ធជូនទៅ គ.ជ.ប។
- ទទួលពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ និងដំណើរការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់។
- ដោះស្រាយរាល់វិវាទកម្មក្រោមសមត្ថកិច្ចរបស់ខ្លួនដូចដែលបានណែនាំដោយ គ.ជ.ប។
- ចាត់គ្រប់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត។
- សហការចាត់ចែងការងារសន្តិសុខបោះឆ្នោតនៅក្នុងរាជធានី ខេត្ត។
- ជូនយោបល់ដល់ គ.ជ.ប អំពីបរិយាកាសក្នុងរាជធានី ខេត្ត ដើម្បីចាត់វិធានការនានា ធានាឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងមានតម្លាភាព។
- វាយតម្លៃអំពីប្រសិទ្ធភាពការងាររបស់សមាជិកទាំងឡាយនៃ គឃ.សប។
- អនុវត្តការងារដទៃទៀត ដែលច្បាប់បោះឆ្នោតអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត។
- អនុវត្តការងារដទៃទៀត ឬអនុវត្តសិទ្ធិអំណាចដទៃទៀត ដែលត្រូវបានប្រគល់ឱ្យដោយ គ.ជ.ប។

**ចំណាំ៖** ភារកិច្ចរបស់ប្រធាន អនុប្រធាន សមាជិក គធ.ខប និងភារកិច្ចរបស់ប្រធាន អនុប្រធាន និងសមាជិក លគធ.ខប មានចែងលម្អិតនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

## II. ការប្រមូល និងការបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត មក គ.ជ.ប

នៅល្ងាចនៃថ្ងៃបោះឆ្នោត ក្រុមសម្របសម្រួលនៃ គធ.ខប ត្រូវ៖

- ចាត់ចែង និងសម្របសម្រួលការអនុវត្តសេចក្ដីសម្រេចរបស់ គ.ជ.ប ស្ដីពីនីតិវិធីនៃការបញ្ជូល បញ្ជូន ត្រួតពិនិត្យ និងផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋម។
- ទាក់ទង និងសហការជាមួយអនុគណៈកម្មការសម្របសម្រួលពាក់ព័ន្ធនឹងរូបភាពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។
- ទាក់ទងជាមួយ គឃ.សប ពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីបញ្ជូល និងបញ្ជូនលទ្ធផលបោះឆ្នោតបឋម។

- ធ្វើការផ្សព្វផ្សាយនូវលទ្ធផលបោះឆ្នោតបឋមនៅក្នុងរាជធានី ខេត្តរបស់ខ្លួន តាមរយៈ Facebook Page របស់ លគធ.ខប និងវិទ្យុក្នុងរាជធានី ខេត្ត បន្ទាប់ពីទទួលបានពីអនុគណៈកម្មការផ្សព្វផ្សាយនៃ គ.ជ.ប។ ការផ្សព្វផ្សាយនេះ អាចធ្វើឡើងដំណាលគ្នានឹងការផ្សព្វផ្សាយរបស់ គ.ជ.ប។

## III. ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យសម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ។

### ១. ទីតាំងនៃមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប

មជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត អាចមានទីតាំងនៅលេខាធិការដ្ឋាននៃ គធ.ខប ឬនៅអគារមួយផ្សេង ឬផ្នែកណាមួយដែលមានទំហំទូលាយល្មមអាចរៀបចំឱ្យមានកន្លែងបម្រុង ដូចខាងក្រោម ៖

- កន្លែងសម្រាប់ទទួលកញ្ចប់ «គ ពិសេស» និងស្បោង «គ» ឬស្បោង «គ មានបណ្ដឹង» និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ពីគ្រប់ឃុំ សង្កាត់ក្នុងរាជធានី ខេត្តពាក់ព័ន្ធដែលត្រូវស្ថិតនៅក្បែរផ្លូវចូល។
- បន្ទប់មួយទូលាយល្មមដែលអាចស្តុកកញ្ចប់ «គ ពិសេស» និងស្បោង «គ» ឬស្បោង «គ មានបណ្ដឹង» ដាច់ដោយឡែកពីគ្នាទៅតាមឃុំ សង្កាត់ និងមានសរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗផង។
- បន្ទប់មួយដោយឡែកដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែល គឃ.សប បានប្រគល់ឱ្យ។
- បន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើន ដែលត្រូវមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើក្នុងពេលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ហើយដែលអាចទទួលបានទាំងក្រុមត្រួតពិនិត្យលទ្ធផលរបស់ គធ.ខប ទាំងតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ ទាំងអ្នកប្ដឹងពាក់ព័ន្ធ ឬតំណាង។
- បន្ទប់ស្អាតតូចមួយ (បើមាន) សម្រាប់ដាក់គ្រឿងបរិក្ខារ កុំព្យូទ័រមួយសម្រាប់បំពាក់ដោយកម្មវិធី និងទម្រង់ឯកភាពមួយសម្រាប់បញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងមានភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត ដើម្បីបញ្ជូនលទ្ធផលទៅ គ.ជ.ប។

## ២. សន្តិសុខ និងសុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត

គធ.ខប ត្រូវធានាអំពីសន្តិសុខ សុវត្ថិភាពនៃអគារមជ្ឈមណ្ឌលរបស់ គធ.ខប សម្រាប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។ នៅក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត គធ.ខប ត្រូវចាត់ចែងដូចខាងក្រោមៈ

- ត្រូវចាត់ឱ្យមានមន្ត្រីម្នាក់ទទួលបន្ទុកសណ្តាប់ធ្នាប់ក្នុងមជ្ឈមណ្ឌល និងត្រូវមានមន្ត្រីម្នាក់ប្រចាំការនៅមាត់ទ្វារចេញចូល ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន គធ.ខប។
- ត្រូវបិទទ្វារ និងបង្អួចទាំងអស់ និងចាក់សោយ៉ាងត្រឹមត្រូវ នៅពេលផុតម៉ោងធ្វើការងារ។
- ត្រូវស្នើសុំកិច្ចសហការពីគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់កម្លាំងការពារបរិវេណខាងក្រៅ។
- ត្រូវរៀបចំចាត់កម្លាំងសន្តិសុខផ្ទាល់របស់ គធ.ខប ដើម្បីការពារបរិវេណខាងក្នុង។

## ៣. ការគ្រប់គ្រងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត

គធ.ខប ត្រូវទទួលបន្ទុកគ្រប់គ្រងការចេញចូលមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងមានសិទ្ធិអំណាចចេញ ចូលមជ្ឈមណ្ឌលនេះ។

ជនគ្រប់រូបដែលមានវត្តមាននៅក្នុងបរិវេណសន្តិសុខ និងក្នុងមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គធ.ខប ។

### ក. ការអនុញ្ញាត

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងមជ្ឈមណ្ឌលនេះនូវជនទាំងឡាយ ដូចខាងក្រោមៈ

- ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដែលបានទទួលការតែងតាំង។
- តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកយកព័ត៌មាន និងអ្នកប្តឹង។
- ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន ឬតំណាង គធ.ខប សំណូមពរក្នុងករណីចាំបាច់។
- មន្ត្រីនៃ គ.ជ.ប ដែលកំពុងបំពេញភារកិច្ចស៊ើបអង្កេតអំពើល្មើស ដែលគេបានចោទប្រកាន់ចំពោះសមាជិក ឬមន្ត្រីនៃ គធ.ខប ដែលចាត់ឱ្យជួយក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។

ខ. បម្រាម

ហាមជនគ្រប់រូបចូលក្នុងមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តៈ

- ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ។
- ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃ គធ.ខប បំពេញចិត្ត ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

## IV. ការប្រគល់ និងការទទួលកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬ/និងស្បោង «គ មានបណ្ដឹង» និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គធ.ខប

១. ការប្រគល់

នៅពេលមកដល់មជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ភ្លាម ប្រធាន គឃ.សប ត្រូវប្រគល់ទៅឱ្យមន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារនៃ គធ.ខប នូវៈ

- កញ្ចប់ «គ ពិសេស» រាល់ស្បោង «គ» និងស្បោង «គ មានបណ្ដឹង» និងរាល់កញ្ចប់ដែលមានវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។
- លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ពាក់ព័ន្ធ។

២. ការទទួល

ដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) ដែលប្រធាន គឃ.សប បានប្រគល់ឱ្យ មន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារត្រូវៈ

- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ នូវកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬស្បោង «គ មានបណ្ដឹង» ទាំងអស់ និងស្បោងសម្ភារ ឯកសារផ្សេងៗទៀត ដោយផ្អែកលើ ទ.១១០៧ ដែលមានក្នុងកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬស្បោង «គ មានបណ្ដឹង» ក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ ឬស្បោងទាំងនោះ និងដែលប្រធាន គឃ.សប បានប្រគល់ជូន។
- ចុះហត្ថលេខាលើ ទ.១១០៧ ពាក់ព័ន្ធ ដោយបញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ (ប្រសិនបើត្រួតពិនិត្យឃើញថាត្រឹមត្រូវហើយ)។
- អញ្ជើញតំណាងគណបក្សនយោបាយពាក់ព័ន្ធចូលរួមចុះហត្ថលេខា ជាសាក្សីលើ ទ.១១០៧។ ការមិនព្រមចុះហត្ថលេខាជាសាក្សីលើលិខិតបញ្ជូន និងប្រគល់ទទួលខាងលើពីតំណាងគណបក្សនយោបាយមិនអាចចាត់ទុក ទ.១១០៧ ពាក់ព័ន្ធនេះជាមោឃៈបានឡើយ។

- កត់ត្រាមុខសម្ភារដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីទទួលសម្ភារ ឯកសាររបស់ខ្លួន ដោយត្រូវចារថា «ការប្រគល់គ្រប់ចំនួន»។ ប្រសិនបើមានស្បោង «គ» ណាមួយ ឬច្រើនមានសរសេរសម្គាល់ថា «មានបណ្តឹង» ត្រូវចារបន្ថែមក្នុងបញ្ជីទទួលសម្ភារ ឯកសាររបស់ខ្លួនថា «មានបណ្តឹង» និងត្រូវ៖
  - ស្រង់កត់ត្រាឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់។
  - យកកញ្ចប់ «គ ពិសេស» និងស្បោង «គ» ដែលមានសរសេរសម្គាល់ថា «គ មានបណ្តឹង» នៃឃុំ សង្កាត់ពាក់ព័ន្ធ ទៅរក្សាទុកដោយឡែកនៅក្នុងបន្ទប់ស្តុក ដើម្បីងាយស្រួលរក។
- ចាត់ចែងប្រើប្រាស់ ទ.១១០៧ ដែលបានចុះហត្ថលេខារួច ដូចខាងក្រោម៖

*ទ.១១០៧ ចំនួន ៣ច្បាប់*
- *១ច្បាប់ ជូនប្រធាន គឃ.សប វិញ*
- *១ច្បាប់ រក្សាទុកជាឯកសារ*
- *១ច្បាប់ ដាក់ចូលក្នុងហោប៉ៅក្រៅកញ្ចប់ «គ ពិសេស» ឬស្បោង «គ» ឬស្បោង «គ មានបណ្តឹង»ពាក់ព័ន្ធ*

- ចាត់ចែង និងណែនាំសហការីរបស់ខ្លួនដែលទទួលបន្ទុករក្សាស្តុក ឱ្យ៖
  - នាំយកកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬស្បោង «គ មានបណ្តឹង» ទៅរក្សាទុកក្នុងបន្ទប់ស្តុកកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬស្បោង «គ មានបណ្តឹង»។
  - នាំយកកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ទៅរក្សាទុកនៅក្នុងបន្ទប់មួយសម្រាប់រក្សាទុកសម្ភារ ឯកសារនៅសល់ ដែលបានត្រៀមទុកស្រាប់។
  - បែងចែក និងរក្សាទុកមុខសម្ភារ ឯកសារដោយឡែកពីគ្នាតាមឃុំ សង្កាត់ ព្រមទាំងត្រូវសរសេរលេខកូដឃុំ សង្កាត់នីមួយៗផង។
- រាយការណ៍អំពីចំនួនកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬស្បោង «គ មានបណ្តឹង» និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ដែលបានទទួលពីគ្រប់ឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ហើយត្រូវបញ្ជាក់ឱ្យច្បាស់នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្តឹង ជូន គធ.ខប ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យត្រួតពិនិត្យលទ្ធផលទៅតាមករណីជាក់ស្តែងនីមួយៗ។
- យកស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) តាមឃុំ សង្កាត់ ដើម្បីបញ្ជូនឱ្យប្រធាន គធ.ខប ចាត់ចែងបូកសរុបចំនួនអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន រួចបញ្ជូនទៅ គ.ជ.ប។

## V. ការដាក់ និងការទទួលពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់ គឃ.សប នៅ គធ.ខប

### ១. អ្នកមានសិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់

ភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលទទួលបានការអនុញ្ញាតឱ្យសង្កេតមើលការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ណាមួយ ឬតំណាងដែលមិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់ គឃ.សប លើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ មានសិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់ គឃ.សប ទៅ គធ.ខប។

### ២. ការបំពេញពាក្យបណ្ដឹង (ទ.១២០២)

| អ្នកប្ដឹងត្រូវ៖ | |
|---|---|
| | - *សុំ ទ.១២០២ សម្រាប់បំពេញពាក្យបណ្ដឹងចំនួន ៣ច្បាប់ពី គឃ.សប។*<br>- *បំពេញ និងផ្ដល់ព័ត៌មានចាំបាច់លើ ទ.១២០២ គ្រប់ច្បាប់ រួចចុះហត្ថលេខា ឬផ្ដិតមេដៃ។*<br>- *យក ទ.១២០២ ទៅដាក់នៅ គធ.ខប តាមរយៈពេលកំណត់។* |

ព័ត៌មានចាំបាច់មួយចំនួនដែលត្រូវបំពេញក្នុង ទ.១២០២ រួមមាន៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង។
- លក្ខណៈសម្គាល់នៃ គឃ.សប ឬ/និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។
- ពេលវេលានៃការកើតឡើង និងប្រភេទនៃកំហុស ឬភាពមិនប្រក្រតី។
- កម្មវត្ថុនៃការប្ដឹងតវ៉ា ឬជំទាស់នឹងសេចក្ដីសម្រេចរបស់ គឃ.សប។
- ប្រសិនបើអាចធ្វើបាន ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ត.រ ឬ ប.ន.ត.រ ដែលត្រូវបានរំលោភ។
- មនុស្សដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តកំហុស ឬភាពមិនប្រក្រតីនេះ។
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន។
- សេចក្ដីអះអាងគាំទ្រ ឬភស្តុតាងផ្សេងទៀត បើមាន។
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង បើមាន។

### ៣. ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គធ.ខប

អ្នកប្ដឹងត្រូវយកពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ច្បាប់ដែលបានបំពេញរួចទៅដាក់នៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) បដិសេធពាក្យបណ្ដឹង។ ក្នុងរយៈពេលកំណត់នេះ បើ គធ.ខប មិនបានទទួលពាក្យបណ្ដឹងចាត់ទុកថា គ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ឡើយ។

## ក. ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់

**ប្រធាន គធ.ខប ឬ សមាជិកដែលបាន ទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវៈ** →

- ណែនាំអ្នកប្ដឹងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងពេលនៃការដាក់ពាក្យបណ្ដឹង
- កត់ត្រាក្នុងកំណត់ហេតុ
- ក្នុងករណីដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតខាងលើ ប្រធាន គធ.ខប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់មូលហេតុ
- ចុះហត្ថលេខា បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទលើ ទ.១២០២ គ្រប់ច្បាប់ និងត្រូវប្រើប្រាស់ដូចខាងក្រោមៈ

  ទ.១២០២ ចំនួន ៣ច្បាប់
  - ១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
  - ១ច្បាប់ ផ្ញើជូន គ.ជ.ប
  - ១ច្បាប់ រក្សាទុកជាឯកសារ
- ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ានឹងការបដិសេធរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលការបដិសេធ។

## ខ. ពាក្យបណ្ដឹងដែលបានទទួលនៅ គធ.ខប ក្រោយរយៈពេលកំណត់

**ប្រធាន គធ.ខប ឬ សមាជិកដែលបាន ទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវៈ** →

- ចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ។
- ចុះហត្ថលេខា បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទឱ្យបានច្បាស់លាស់ លើ ទ.១២០២ គ្រប់ច្បាប់ និងត្រូវប្រើប្រាស់ដូចខាងក្រោមៈ

  ទ.១២០២ ចំនួន ៣ច្បាប់
  - ១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
  - ១ច្បាប់ ផ្ញើជូន គ.ជ.ប
  - ១ច្បាប់ រក្សាទុកជាឯកសារ
- ជម្រាបអ្នកប្ដឹងថា ពាក្យបណ្ដឹងរបស់គាត់បានដាក់នៅក្រោយរយៈពេលកំណត់ គធ.ខប មិនអាចទទួលយកមកដោះស្រាយបានទេ។

### គ. ពាក្យបណ្តឹងដែលបានទទួលនៅ គធ.ខប ក្នុងរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់គ្រប់គ្រាន់

*ប្រធាន គធ.ខប ឬ សមាជិកដែលបាន ទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវ៖*

- *ចុះកាលបរិច្ឆេទ ពេលវេលា រួចចុះហត្ថលេខា និងបោះត្រា គធ.ខប លើ ទ.១២០២ ទាំង ៣ច្បាប់ និងត្រូវប្រើប្រាស់ដូចខាងក្រោម៖*

  *ទ.១២០២ ចំនួន ៣ច្បាប់*
  - *១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង*
  - *១ច្បាប់ បិទផ្សាយជាសាធារណៈនៅលគធ.ខប*
  - *១ច្បាប់ ទុកប្រើក្នុងការសម្រេចលើពាក្យបណ្តឹង*
- *ជម្រាបអ្នកប្តឹង ឬតំណាងថា គធ.ខប នឹងសម្រេចលើពាក្យបណ្តឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធនឹងបណ្តឹងនោះ*
- *រាយការណ៍អំពីករណីបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ខាងលើនេះជាបន្ទាន់ជូនប្រធាន គធ.ខប ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានពាក្យបណ្តឹងនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាងពាក់ព័ន្ធ។*

**ចំណាំ៖** - គធ.ខប ត្រូវសម្រេចលើពាក្យបណ្តឹងដែលបានទទួលនៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។

- ប្រធាន គធ.ខប អាចប្រគល់សិទ្ធិទទួលពាក្យបណ្តឹងជូនដល់សមាជិកណាម្នាក់ ដោយត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវ។

## VI. ប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

បន្ទាប់ពីបានទទួលកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬ/និងស្បោង «គ មានបណ្តឹង» នៃឃុំ សង្កាត់មួយចំនួនហើយ គធ.ខប ត្រូវចាត់វិធានការជាបណ្តើរៗ ដូចខាងក្រោម៖

### ១. ការណែនាំក្រុមត្រួតពិនិត្យលទ្ធផល

- ឱ្យត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ដែលខ្លួនទទួលបន្ទុក តាមករណីនីមួយៗ ដោយឡែកពីគ្នា ទាំងឃុំ សង្កាត់គ្មានពាក្យបណ្តឹង ទាំងឃុំ សង្កាត់មានពាក្យបណ្តឹង។

- ការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្តត្រូវធ្វើឱ្យបានរួចរាល់ឆាប់រហ័ស និងមិនឱ្យហួសរយៈពេល ៥ថ្ងៃឡើយ (គិតទាំងការបូកសរុបរបស់ក្រុមបូកសរុបលទ្ធផល) ដោយចាប់រាប់ពីថ្ងៃបានទទួលកញ្ចប់ «គ ពិសេស» ស្បោង «គ» ឬ/និងស្បោង «គ មានបណ្តឹង»។
- ប្រសិនបើចាប់ផ្តើមត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយពុំត្រូវឈប់សម្រាកឡើយ ជាពិសេសចំពោះឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរដែលតម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផលបើកកញ្ចប់សុវត្ថិភាព «ក» មួយ ឬច្រើន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។
- ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខបចំនួន ២ ឬច្រើនក្រុមអាចត្រួតពិនិត្យលទ្ធផលជុំគ្នានៅក្នុងបន្ទប់តែមួយ តែនៅតាមតុដោយឡែកពីគ្នា ទៅតាមលទ្ធភាពជាក់ស្តែងរបស់រាជធានី ខេត្ត។

### ២. ការកំណត់ និងការរៀបចំតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងអ្នកប្តឹង ឬតំណាង ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលរាល់ដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ក្នុងរាជធានី ខេត្ត តាមការកំណត់ និងរៀបចំ ដូចខាងក្រោម៖

- តំណាងគណបក្សនយោបាយនីមួយៗ និងអ្នកសង្កេតការណ៍នៃអង្គការនីមួយៗប្រចាំការតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ត្រូវជ្រើសតាំងឱ្យមានតំណាងពេញសិទ្ធិ និងតំណាងបម្រុងតាមចំនួនដែល គធ.ខប បានកំណត់ ដែលអាចចូលរួមគ្រប់គ្រាន់ល្មម ក្នុងការសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប។
- តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍អាចផ្លាស់ប្តូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួន។
- តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាង ត្រូវបានរៀបចំឱ្យស្ថិតនៅជិត ល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ក្នុងរាជធានី ខេត្ត។

**ចំណាំ៖** តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកប្តឹង ឬតំណាង អាចថតយករូបភាពនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

### ៣. ការកំណត់ និងការរៀបចំបន្ទប់សម្រាប់ក្រុមត្រួតពិនិត្យលទ្ធផល

*គធ.ខប ត្រូវ៖*

- *កំណត់ចំនួនបន្ទប់ ដើម្បីតម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផលបំពេញការងារ។*
- *រៀបចំតុ កៅអីឱ្យមានចំនួនគ្រប់គ្រាន់សម្រាប់ក្រុមនីមួយៗ និងកៅអីសម្រាប់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្ដឹង ឬតំណាង (បើមាន)។*
- *ណែនាំក្រុមត្រួតពិនិត្យឱ្យរៀបចំគំរូប្លង់ (ដូចគ្នានឹងគំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោត)។*
- *ឱ្យមានសម្ភារ ឯកសារគ្រប់គ្រាន់សម្រាប់ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ។*




## VII. ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់

ក្នុងករណីឃុំ សង្កាត់ណាគ្មានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប និងនៅ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្តដូចខាងក្រោម៖

*ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប*

- *មិនត្រូវបើកកញ្ចប់សុវត្ថិភាព «ក» ណាមួយឡើយ។*
- *គ្រាន់តែធ្វើការត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) តែប៉ុណ្ណោះ។*

## ១. ដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត

គធ.ខប ត្រូវធានាថា ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងទាំងអស់ក្នុងរាជធានី ខេត្ត ត្រូវបានអនុវត្តម្តងមួយឃុំ សង្កាត់ៗ ជាបន្តបន្ទាប់រហូតដល់អស់ឃុំ សង្កាត់គ្មានពាក្យបណ្តឹង និងតាមលំដាប់លំដោយ នៃនីតិវិធី ដូចខាងក្រោម៖

**ប្រធានក្រុមត្រូវ៖**

- *បង្គាប់ជំនួយការឱ្យយកកញ្ចប់ គ ពិសេស» នៃឃុំ សង្កាត់ដែលគ្មានពាក្យបណ្តឹងម្តងមួយៗពីកន្លែងរក្សាស្តុកមកដាក់លើតុចំពីមុខគាត់។*
- *បើកកញ្ចប់ «គ ពិសេស»រួចដកយកស្រោមសំបុត្រដាក់ ទ.១១០៣ និង ទ.១១០៩ ដែលមានកាខ្នងថា «ផ្ញើជូន គធ.ខប» មកដាក់លើតុ។*
- *ដកយករាល់ស្រោមសំបុត្រដាក់ ទ.១១០១ និង ទ.១១០២ ដែលមានកាខ្នងថា «ផ្ញើជូន គធ.ខប» មកដាក់លើតុ។*
- *ដកយកស្រោមសំបុត្រ ទ.១១០៣ និង ទ.១១០៩ ដែលមានកាខ្នងថា «ផ្ញើជូន គ.ជ.ប» ជូនប្រធាន លគធ.ខប ដើម្បីប្រមូលដាក់ក្នុងកញ្ចប់ «ឃ ពិសេស»។*
- *ដាក់កញ្ចប់ «គ ពិសេស» ទទេនៅក្បែរខ្លួន។*
- *ចាត់ចែងសមាជិកឱ្យត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលដោយផ្អែកលើ ទ.១១០៣ និង ទ.១១០៩។*
- *ត្រួតពិនិត្យផ្ទៀងផ្ទាត់បន្ថែមទៀតជាមួយ ទ.១១០១ និង ទ.១១០២ នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ (បើមានភាពមិនច្បាស់លាស់)។*
- *ធានាថា ទ.១១១៦គព ទាំង ២ច្បាប់ ដែលអនុប្រធាន និងលេខាធិការបានបំពេញ ត្រូវបានផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយគ្នា និងមានបញ្ជាក់ច្បាស់នូវ៖*
  - *ឈ្មោះ និងលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ។*
  - *ខ្លឹមសារដូចខាងក្រោម ប្រសិនបើរកឃើញថា៖*
    - *តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់មានភាពត្រឹមត្រូវ។*
    - *គឃ.សប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផល។*
- *ធានាថា ទ.១១១៦គព ទាំង ២ច្បាប់ ត្រូវបានចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល។*
- *ដាក់ ទ.១១១៦គព + ទ.១១០៣ + ទ.១១០៩ ក្នុងស្រោមសំបុត្រដដែល ជូនប្រធាន គធ.ខប ពិនិត្យសម្រេច តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស។*

**ចំណាំ៖** បើ គយ.សប មានកំហុសក្នុងការគណនាបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ប្រធានក្រុមត្រួតពិនិត្យត្រូវ៖

- បង្ហាញកំហុសនោះ និងការកែតម្រូវ ព្រមទាំងហេតុផលនៃការកែតម្រូវនោះនៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។
- ឆូតលើតួលេខដែលខុស តែមិនត្រូវធ្វើឱ្យបាត់លក្ខណៈសម្គាល់នៃតួលេខដើមទេ រួចសរសេរតួលេខថ្មីដែលត្រឹមត្រូវនៅក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង។

**២. ការពិនិត្យសម្រេចរបស់ គធ.ខប នៅលើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦តព) និងការប្រើប្រាស់**

ប្រសិនបើ គធ.ខប ពិនិត្យលើឯកសារដែលក្រុមត្រួតពិនិត្យលទ្ធផលបានប្រគល់ជូននោះឃើញថា មានភាពត្រឹមត្រូវហើយ ប្រធាន គធ.ខប ត្រូវ៖

- ចារយល់ព្រមចុះហត្ថលេខាបោះត្រានិងចុះកាលបរិច្ឆេទលើ ទ.១១១៦តព ទាំង២ច្បាប់។
- ដាក់បង្ហាញ ទ.១១១៦តព ចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍។
- ទ.១១១៦តព ត្រូវប្រើប្រាស់ដូចខាងក្រោម៖

ទ.១១១៦តព ចំនួន ២ច្បាប់
- *១ច្បាប់ + ទ.១១០៣ + ទ.១១០៩ ច្រកចូលក្នុងស្រោមសំបុត្រដូចដើម ហើយជូនក្រុមត្រួតពិនិត្យលទ្ធផលដើម្បីរក្សាទុក*
- *១ច្បាប់ ដាក់កញ្ចប់ «ឃ ពិសេស» ផ្ញើជូន គ.ជ.ប*

**៣. ការរៀបចំសម្ភារ ឯកសារឡើងវិញ**

ប្រធាន គធ.ខប ត្រូវធានាថា៖

- រាល់ស្រោមសំបុត្រដាក់ ទ.១១០៣ និង ទ.១១០៩ ផ្ញើជូន គ.ជ.ប ដែលប្រធានក្រុមត្រួតពិនិត្យលទ្ធផលបានដកយកពីកញ្ចប់ «គ ពិសេស» នីមួយៗ និងបានប្រគល់ជូន គធ.ខប ត្រូវប្រមូលដាក់ឱ្យអស់ទៅក្នុងកញ្ចប់ «ឃ ពិសេស» ដែលត្រៀមបម្រុងជាស្រេចទុកផ្ញើជូន គ.ជ.ប។
- ទ.១១១៦តព (១ច្បាប់) ទ.១១០៣ និង ទ.១១០៩ នៃឃុំ សង្កាត់នីមួយៗត្រូវបានច្រកចូលក្នុងស្រោមសំបុត្រដើម ហើយប្រមូលដាក់ក្នុងកញ្ចប់ «គ ពិសេស» រួចយកទៅរក្សាទុកនៅកន្លែងស្តុកវិញ ដែលត្រូវរក្សាទុកជាឯកសាររបស់ គធ.ខប។
- ទ.១១០១ និង ទ.១១០២ នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ពាក់ព័ន្ធត្រូវបានច្រកចូលក្នុងស្រោមសំបុត្រដើម ហើយប្រមូលដាក់ចូលក្នុងកញ្ចប់ «គ ពិសេស» និងរក្សាទុកជាឯកសារនៅ គធ.ខប។

## VIII. ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ដាក់នៅ គឃ.សប និងនៅ គធ.ខប

ក្នុងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប ហើយពាក្យបណ្ដឹងនោះត្រូវបានដាក់ប្ដឹងបន្តនៅ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្ត ដូចខាងក្រោមៈ

| | |
|---|---|
| *ក្រុមត្រួតពិនិត្យលទ្ធផលត្រូវៈ* | *- ត្រួតពិនិត្យជាមុននូវសេចក្ដីសម្រេចរបស់ គឃ.សប លើពាក្យបណ្ដឹងពាក់ព័ន្ធ។*<br>*- ពិនិត្យរបាយការណ៍របស់ គឃ.សប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមាន)។*<br>*- ពិនិត្យលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធដែលត្រូវបានដាក់នៅ គធ.ខប។*<br>*- លើកយោបល់ស្នើទៅ គធ.ខប ដើម្បីសម្រេចអនុញ្ញាតឱ្យបើក ឬមិនអនុញ្ញាតឱ្យបើកកញ្ចប់សុវត្ថិភាព «ក» នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។* |

### ១. ករណីគ្មានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬពុំមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត

ក្នុងករណីនេះ គធ.ខប មិនចាំបាច់តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតឡើយ។ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តតាមនីតិវិធីទាំងស្រុង ដូចករណីឃុំ សង្កាត់ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ (សូមមើល និងអនុវត្តទាំងស្រុងតាមចំណុច VII)។

### ២. ករណីមានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោត

ក្នុងករណីនេះ គធ.ខប ត្រូវអនុញ្ញាតឱ្យបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។

#### ក. នីតិវិធីនៃការបើកកញ្ចប់សុវត្ថិភាព «ក»

| | |
|---|---|
| *ជាដំបូង ក្រុមត្រួតពិនិត្យលទ្ធផល ត្រូវៈ* | *ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ដោយអនុវត្តដូចឃុំ សង្កាត់គ្មានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ (សូមមើល និងអនុវត្តតាមចំណុច១ ក្រោមចំណុច VII)។* |

| | |
|---|---|
| បន្ទាប់មក ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តបន្ថែមដោយ៖ | - បង្គាប់ជំនួយការឱ្យយកស្បោង «គ មានបណ្តឹង» នៃឃុំ សង្កាត់ពាក់ព័ន្ធពីបន្ទប់រក្សាស្តុក មកដាក់លើតុចំពីមុខខ្លួន។<br>- កាត់សោឃ្លុំបើកស្បោង «គ មានបណ្តឹង» នោះ ដកយកស្បោង «ខ» ពាក់ព័ន្ធចេញមកក្រៅ។<br>- បើកស្បោង «ខ» ដកយកកញ្ចប់សុវត្ថិភាព «ក» មកដាក់លើតុ។<br>- ប្រើកន្ត្រៃកាត់បើកកញ្ចប់សុវត្ថិភាព «ក» ដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែលមានក្នុងកញ្ចប់សុវត្ថិភាព «ក» មកដាក់ដោយឡែកពីគ្នានៅលើតុខាងមុខគាត់។<br>- ប្រគល់ ទ.១១០១ ទ.១១០២ និង ទ.១១០៨ ទៅឱ្យលេខាធិការសម្រាប់តាមដានពិនិត្យ ដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។<br>- បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកម្តងមួយៗ ដើម្បីយកសម្ភារ ឯកសារបោះឆ្នោតមកត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ។<br>- នៅពេលមាន ទ.១១០១ ទ.១១០២ និង ទ.១១០៨ ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ និងបញ្ហាជារួមដូចខាងក្រោម៖<br>▪ ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។<br>▪ ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។<br>▪ ពិនិត្យ និងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានមកបោះឆ្នោត។<br>▪ ពិនិត្យផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះ ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលទទួលពីការិយាល័យបោះឆ្នោតមកវិញ។<br>▪ រាប់ចំនួនសន្លឹកឆ្នោតខូច (បើមាន)។<br>▪ រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ។<br>▪ ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ។<br>▪ ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ។<br>▪ ពិនិត្យមើលថា តើក្នុង ទ.១១០១ និង ទ.១១០២ មានចុះអំពីភាពមិនប្រក្រតីដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតដែរឬទេ?<br>▪ ពិនិត្យមើលថា តើក្នុង ទ.១១០១ និង ទ.១១០២ មានភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខាជាសាក្សីដែរ ឬទេ? |

ចំណាំ៖ - ក្នុងករណីចាំបាច់ គធ.ខប អាចធ្វើការស៊ើបអង្កេតស្រាវជ្រាវលើពាក្យបណ្ដឹង មុននឹងសម្រេចឱ្យបើក ឬមិនបើកកញ្ចប់សុវត្ថិភាព «ក»។

- បើ គធ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព «ក» នៃការិយាល័យបោះឆ្នោតលើសពីមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តការងារនេះតាមលំនាំនីតិវិធីដដែល សម្រាប់កញ្ចប់សុវត្ថិភាព «ក» នីមួយៗ រហូតទាល់តែអស់កញ្ចប់សុវត្ថិភាព «ក» ដែលត្រូវបើក។

## ខ. របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត

បន្ទាប់ពីបើកកញ្ចប់សុវត្ថិភាព «ក» នៃការិយាល័យបោះឆ្នោតណាមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរួច ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែង៖

- ធ្វើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតចំនួន ២ច្បាប់ ដែលត្រូវ៖
  - ចុះហត្ថលេខា ដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល។
  - លើកយោបល់ស្នើសុំ គធ.ខប ពិនិត្យសម្រេចតាមរយៈប្រធានអនុគណៈ-កម្មការបច្ចេកទេស ៖
    - យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ឬ
    - យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ករណីរកឃើញកំហុសឆ្គងក្នុងការគណនាលេខ ឬ
    - ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (សុំរាប់សន្លឹកឆ្នោតឡើងវិញ ឬសុំបោះឆ្នោតសាជាថ្មី)។
- ចារលើរបាយការណ៍របស់ គឃ.សបស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយបញ្ជាក់ខ្លឹមសារស្របទៅនឹងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល។

## គ. ឯកសារដែលត្រូវដាក់ជូន គធ.ខប ដើម្បីសម្រេច

ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវដាក់ជូន គធ.ខប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស នូវ៖

- របាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលទាំង ២ច្បាប់។

- សេចក្តីសម្រេចរបស់ គឃ.សប លើពាក្យបណ្តឹងពាក់ព័ន្ធ + របាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» (បើមាន)។
- ទ.១១១៦គព ចំនួន ២ ច្បាប់ + ទ.១១០៣ + ទ.១១០៩។

**ឃ. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតឡើងវិញ**

- ដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ទៅក្នុងស្បោងប្លាស្ទិក និងស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ចប់ដាក់ក្នុងកញ្ចប់សុវត្ថិភាព «ក» តាមលំនាំដើមវិញ។
- ដាក់កញ្ចប់សុវត្ថិភាព «ក» ទៅក្នុងស្បោង «ខ» រួចចងភ្ជិត។
- ដាក់ស្បោង «ខ» ចូលទៅក្នុងស្បោង «គ មានបណ្តឹង» តាមលំនាំដើម និងចាក់សោឃ្លុំមានលេខ រួចនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប។

**៣. ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់**

គធ.ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង បន្ទាប់ពីក្រុមត្រួតពិនិត្យបានត្រួតពិនិត្យលទ្ធផលនៃឃុំ សង្កាត់មានពាក្យបណ្តឹងរួចរាល់ហើយ ដោយផ្អែកលើ៖

- របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតទាំង ២ច្បាប់របស់ក្រុមត្រួតពិនិត្យលទ្ធផល។
- សេចក្តីសម្រេចរបស់ គឃ.សប លើពាក្យបណ្តឹងពាក់ព័ន្ធ (បើមាន)។
- របាយការណ៍របស់ គឃ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមាន)។
- ទ.១១១៦គព ចំនួន ២ច្បាប់ + ទ.១១០៣ + ទ.១១០៩។
- ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែល គធ.ខប បានទទួល។

**ក. ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់**

ប្រធាន គធ.ខប ត្រូវ៖

- ចារយល់ព្រមលើ ទ.១១១៦គព ទាំង ២ច្បាប់របស់ក្រុមត្រួតពិនិត្យលទ្ធផល។
- ចារយល់ព្រមលើរបាយការណ៍ទាំង ២ច្បាប់ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប។
- ចារយល់ព្រមលើសម្រង់សេចក្តីសម្រេចរបស់ គឃ.សប ដែលបានបដិសេធពាក្យបណ្តឹងពាក់ព័ន្ធ និងទទួលយកលទ្ធផលនៃការបោះឆ្នោត ឬចារបដិសេធ

លើសម្រង់សេចក្តីសម្រេចរបស់ គឃ.សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងពាក់ព័ន្ធ ដោយធ្វើការកែតម្រូវលទ្ធផលនៃការបោះឆ្នោត ឬបដិសេធលទ្ធផលនៃការបោះឆ្នោត។

- ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ខប លើឯកសារខាងលើ។
- ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ឱ្យបំពេញ ទ.១២០៣ របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលត្រូវបដិសេធពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលដាក់នៅ គធ.ខប ដោយបញ្ជាក់ច្បាស់ពីមូលហេតុ។
- ចុះហត្ថលេខាលើ ទ.១២០៣ ដោយសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងខ្លួនគាត់ ចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប។ ទ.១២០៣ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

ទ.១២០៣ ចំនួនគ្រប់គ្រាន់
- *១ច្បាប់ ប្រគល់ជូនអ្នកប្តឹង ឬតំណាង*
- *១ច្បាប់ ជូនតំណាងគណបក្សនយោបាយឈរឈ្មោះនីមួយៗ*
- *១ច្បាប់ ផ្ញើជូន គ.ជ.ប*
- *១ច្បាប់ ផ្ញើជូន គឃ.សប ពាក់ព័ន្ធ*
- *១ច្បាប់ រក្សាទុកជាឯកសារនៅ គធ.ខប*

- ជម្រាបអ្នកប្តឹង ឬតំណាងថា គាត់មានសិទ្ធិប្តឹងទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ខប។
- ជូន ទ.១២០២ ចំនួន ៣ច្បាប់ ជូនអ្នកប្តឹង ឬតំណាង បើគាត់ស្នើសុំ។
- ប្រគល់ជូនក្រុមបូកសរុបលទ្ធផលនៃ គធ.ខប ដើម្បីបន្តអនុវត្តភារកិច្ចរបស់ខ្លួននូវ ទ.១១១៦គព ចំនួន ១ច្បាប់ + របាយការណ៍បើកកញ្ចប់សុវត្ថិភាព «ក» របស់ គធ.ខប ចំនួន ១ច្បាប់ + សម្រង់សេចក្តីសម្រេចរបស់ គឃ.សប ចំនួន ១ច្បាប់ (បើមាន) + សម្រង់សេចក្តីសម្រេចរបស់ គធ.ខប ចំនួន ១ច្បាប់។
